បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២៧៥០ រៀល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
* * *

ឆ្នាំទី ៧ លេខ ២៦ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្តាហ៍

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


៩-៧-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/២២ តែងតាំងឯកឧត្តម ឌី ឆនិ ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ១២២៣

៩-៧-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/២៣ ត្រូវបានតែងតាំងឯកឧត្តមឧត្តមសេនីយ៍ឯក ឯម សំអាន ជាអគ្គលេខាធិការនៃអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងនឹង គ្រឿងញៀន ១២២៤

៩-៧-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/២៤ ត្រូវបានតែងតាំងឯកឧត្តមឧត្តមសេនីយ៍ទោ ឃូ ស៊ុនឡុង ជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន ១២២៥

៩-៧-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/២៥ ត្រូវបានតែងតាំងឯកឧត្តមឧត្តមសេនីយ៍ត្រី ខៀវ សុគ៌ត ជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន ១២២៥

៩-៧-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/២៦ ត្រូវបានតែងតាំងឯកឧត្តមឧត្តមសេនីយ៍ត្រី លូ រ៉ាមីន ជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន ១២២៦

៩-៧-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/២៧ ត្រូវបានផ្ទេរភារកិច្ច ជាអគ្គលេខាធិការនិង អគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធ ប្រឆាំងនឹងគ្រឿងញៀន ១២២៧

១៥-៧-១៩៩៩ -ព្រះរាជក្រឹត្យជស/រកត/០៧៩៩/៣៦តែងតាំងឯកឧត្តម ពេជ្រ គឹមស្រ៊ាង ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ១២២៨


## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


១២-៧-១៩៩៩ -អនុក្រឹត្យលេខ ៥៩ អនក្រ.បក ស្តីពីការបង្កើត ឃុំភ្នំដី ចំណុះស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ១២២៩

១២-៧-១៩៩៩ -អនុក្រឹត្យលេខ ៦០ អនក្រ.បក ស្តីពីការបង្កើត ឃុំតាគង់ ចំណុះស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ១២៣០

១២-៧-១៩៩៩ -អនុក្រឹត្យលេខ ៦១ អនក្រ.បក ស្ដីពីការបង្កើត ប៉ុស្ដិ៍ប៉ូលីសជាតិ ចំណុះ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ១២៣១
៩-៧-១៩៩៩ -អនុក្រឹត្យលេខ ៤២២ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១២៣២
៩-៧-១៩៩៩ -អនុក្រឹត្យលេខ ៤២៣ អនក្រ.តត ស្ដីពីការផ្ដល់មេដាយមហាសេរីវឌ្ឍន៍ ១២៣៣
៩-៧-១៩៩៩ -អនុក្រឹត្យលេខ ៤២៤ អនក្រ.តត ស្ដីពីការតែងតាំងអភិបាល ស្រុក ខ័ណ្ឌ តាមបណ្ដាខេត្ត ក្រុង ១២៣៤
៩-៧-១៩៩៩ -អនុក្រឹត្យលេខ ៤២៥ អនក្រ.តត ស្ដីពីការផ្លាស់ប្ដូរមន្ត្រីរាជការ ១២៣៤
៩-៧-១៩៩៩ -អនុក្រឹត្យលេខ ៤២៦ អនក្រ.តត ស្ដីពីការតែងតាំងអភិបាល ស្រុក ខ័ណ្ឌតាមបណ្ដាខេត្ត ក្រុង ១២៣៥
៩-៧-១៩៩៩ -អនុក្រឹត្យលេខ ៤២៧ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ ១២៣៦
៩-៧-១៩៩៩ -អនុក្រឹត្យលេខ ៤២៨ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ ១២៣៧
៩-៧-១៩៩៩ -អនុក្រឹត្យលេខ ៤២៩ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ ១២៣៨
៩-៧-១៩៩៩ -អនុក្រឹត្យលេខ ៤៣០ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ ១២៣៩
៩-៧-១៩៩៩ -អនុក្រឹត្យលេខ ៤៣១ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ ១២៤០
៩-៧-១៩៩៩ -អនុក្រឹត្យលេខ ៤៣២ អនក្រ.តត ស្ដីពីការតែងតាំងសមាជិករបស់ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ១២៤១
៩-៧-១៩៩៩ -អនុក្រឹត្យលេខ ៤៣៣ អនក្រ.តត ស្ដីពីការតែងតាំងប្រធានអគ្គនាយក របស់ធនាគារអភិវឌ្ឍន៍ជនបទ ១២៤២
១៤-៧-១៩៩៩ -អនុក្រឹត្យលេខ ៤៣៤ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ ១២៤៣
១៤-៧-១៩៩៩ -អនុក្រឹត្យលេខ ៤៣៥ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ ១២៤៣
១៤-៧-១៩៩៩ -អនុក្រឹត្យលេខ ៤៣៦ អនក្រ.តត ស្ដីពីការផ្ដល់មេដាយសហមេត្រី ១២៤៤
១៤-៧-១៩៩៩ -អនុក្រឹត្យលេខ ៤៣៧ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ ១២៤៥
១៤-៧-១៩៩៩ -អនុក្រឹត្យលេខ ៤៣៨ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ ១២៤៦
១៤-៧-១៩៩៩ -អនុក្រឹត្យលេខ ៤៣៩ អនក្រ.តត ស្ដីពីការផ្ដល់មេដាយសហមេត្រី ១២៤៧

## ២–សេចក្ដីសំរេច

១៣-៧-១៩៩៩ -សេចក្ដីសំរេចលេខ ៥២ សសរ ស្ដីពីការបង្កើតគណៈកម្មការសំរេច ប្រតិបត្តិការវិស័យថាមពលអគ្គិសនីជាមួយក្រុមហ៊ុនទៃ ប្លក់ សៀមរាប ១២៤៨

## ៣–សារាចរ

៩-៧-១៩៩៩ -សារាចរលេខ ០៩ សរ ស្ដីពីការពង្រឹងសណ្ដាប់ធ្នាប់របៀបរៀបរយ នៅពេលប្រជុំ ១២៤៩

## III- ការងារបណ្ណាក្រសួង

### ១-ទីស្ដីការគណៈរដ្ឋមន្ត្រី

#### សេចក្ដីសំរេច

៩-៧-១៩៩៩ -សេចក្ដីសម្រេចលេខ ៧៧ សសរ ស្ដីពីការបំពេញបន្ថែមសេចក្ដីសម្រេចលេខ ២៤ សសរ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពីការបង្កើតគណៈកម្មការអន្តរជាតិក្រសួងសំរាប់ដឹកនាំរៀបចំ និងដំណើរការប្រឡងប្រជែងជ្រើសរើសសិស្សនិស្សិតអោយចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននានា ១២៥១

### ២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

#### ប្រកាស

១២-៧-១៩៩៩ -ប្រកាសលេខ ៦៦៣ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនខេមបូឌា ស៊ុយហ្ស៊ូគីម៉ូទ័រ ( CAMBODIA SUZUKI MOTOR CO. LTD) តំណាងដោយលោក ស៊ីវ ថៃ សញ្ជាតិកម្ពុជា បង្កើតរោងចក្រតម្លើងម៉ូចក្រយានយន្ត ១២៥២

១២-៧-១៩៩៩ -ប្រកាសលេខ ៦៦៤ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន លីនស៍ ធិចស្ទាយល៍ ( LINS TEXTILE CO LTD ) តំណាងដោយលោក LAM CHING - MUI សញ្ជាតិ ចិន ( តៃវ៉ាន់ ) បង្កើតរោងចក្រផលិតក្រណាត់ចាក់ ១២៥៤

១៤-៧-១៩៩៩ -ប្រកាសលេខ ៦៦៦ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនហ្វារអ៊ីសធេកស្ទាយល៍ លីមីធីដ ( FAR EAST TEXILE , LTD ) តំណាងដោយលោក ចាង ជៀនកួ សញ្ជាតិ កម្ពុជា បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ១២៥៥

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/២២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

★ ★ ★

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៥៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

ត្រាស់បង្គាប់

មាត្រា ១ ._ តែងតាំងឯកឧត្តម អ៊ី ឆន ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារអភិវឌ្ឍន៍ជនបទ និងសំណង់ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ ._ ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ភ្នំពេញ.ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

★★★

## ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/២៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់បាលព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៩

**ត្រាស់បង្គាប់**

មាត្រា ១ ._ ត្រូវបានតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ឯក **ឯម សំអាន** ជាអគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ ._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ភ្នំពេញ,ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

***

## ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/២៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

★ ★ ★

- បានទ្រង់ឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានទ្រង់ឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៩

ត្រាស់បង្គាប់

**មាត្រា ១ .**_ ត្រូវបានតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ទោ **យូ ស៊ុនឡុង** ជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀនបន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ .**_ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .**_ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ភ្នំពេញ,ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

ប្រមុខរដ្ឋស្តីទី

**ជា ស៊ីម**

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/២៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

★ ★ ★

- បានទ្រង់ឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៩

**ត្រាស់បង្គាប់**

មាត្រា ១ ._ ត្រូវបានតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ត្រី **ខៀវ សុផ័គ** ជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន បន្ថែមលើមុខងារបច្ចុប្បន្នមានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២ ._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ភ្នំពេញ,ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

ប្រមុខរដ្ឋស្តីទី

**ជា ស៊ីម**

★★★

**ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/២៦**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

★ ★ ★

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៩

**ព្រះរាជក្រឹត្យ**

មាត្រា ១ .- ត្រូវបានតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ត្រី លុ រ៉ាមីន ជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន ទទួលបន្ទុកប្រឆាំងការអធិរាជ្ញកម្ម មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ .- ទីស្តីការគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តដោយបានតាមឲ្យព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ភ្នំពេញ,ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

★★★

**ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/២៧**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

★ ★ ★

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៩

**ព្រះរាជក្រឹត្យ**

មាត្រា ១ .- ត្រូវបានផ្ទេរភារកិច្ច អគ្គលេខាធិការ និងអគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង នឹងគ្រឿងញៀន ទៅទទួលភារកិច្ចថ្មី ជាទីប្រឹក្សាអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន ដោយរក្សាឋានៈដដែល ដូចមានរាយនាមខាងក្រោម ៖

១-ឯកឧត្តម ឆេង ជាវ៉ុង

២-ឯកឧត្តម ឌុន សឿរ

៣-ឯកឧត្តម ស៊ាន វិសុទ្ធ

៩-លោកឧត្តម ម៉ាត់លីរុន ស្មាជាវី

មាត្រា ២ ._ រាល់បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ភ្នំពេញ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

***

## ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/៣៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញ ស្តីពីការវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៥៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសបង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី ២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

**ត្រាស់បង្គាប់**

**មាត្រា ១ ._** តែងតាំងឯកឧត្តម **ពេជ្រ គឹមស្រ៊ាង** ជាទីប្រឹក្សាផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភាទទួលបន្ទុកការងារសាធារណការ និងដឹកជញ្ជូន មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២ ._** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ ._** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩

ប្រមុខរដ្ឋស្តីទី

**ជា ស៊ីម**

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៥៩ អនក្រ.បក
### ស្តីពីការបង្កើត ឃុំភ្នំដី ចំណុះស្រុក
### ភ្នំស្រុក ខេត្តបន្ទាយមានជ័យ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា ១ .-** ត្រូវបានបង្កើតឃុំ ភ្នំដី ចំណុះស្រុកភ្នំស្រុក ខេត្តបន្ទាយជ័យ ដោយកាត់យកភូមិសាស្ត្រមួយចំណែក របស់ឃុំស្រះជីក ក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។

**មាត្រា ២ .-** ឃុំភ្នំដី មានព្រំប្រទល់ដូចតទៅ :

-ខាងជើងទល់ នឹង ព្រំប្រទល់ឃុំណាំតៅ ស្រុកភ្នំស្រុក

-ខាងត្បូងទល់ នឹង ព្រំប្រទល់ឃុំទឹកជោរ ស្រុកព្រះនេត្រព្រះ

-ខាងកើតទល់ នឹង ព្រំប្រទល់ឃុំស្ពានស្រែង ស្រុកភ្នំស្រុក

-ខាងលិចទល់ នឹង ព្រំប្រទល់ឃុំប៉ោយចារ និងឃុំស្រះជីក ស្រុកភ្នំស្រុក

មាត្រា ៣ ._ ទីតាំងស្នាក់ការឃុំថ្មី ស្ថិតក្នុងភូមិថ្មី ។

មាត្រា ៤ ._ បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាននិងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៦០ អនក្រ.បក
## ស្តីពីការបង្កើត ឃុំតានន់ ចំណុះស្រុក
## ម៉ាឡៃ ខេត្តបន្ទាយមានជ័យ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

មាត្រា ១ ._ ត្រូវបានបង្កើត ឃុំតានន់ ចំណុះស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដោយកាត់យកភូមិ[illegible] ចំនួន របស់ឃុំទួលពង្រ ក្នុងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

មាត្រា ២ ._ ឃុំតានន់ មានព្រំប្រទល់ដូចខាងក្រោម :

-ខាងជើងទល់ នឹង ព្រំប្រទល់ឃុំនិមិត្ត ឃុំគុត្តសត និងឃុំសំរោង ស្រុកអូរជ្រៅ

-ខាងត្បូងទល់ នឹង ព្រំប្រទល់ឃុំសឿ ស្រុកមង្គលបូរី

-ខាងកើតទល់ នឹង ព្រំប្រទល់ឃុំចំណោម ស្រុកមង្គលបូរី

-ខាងលិចទល់ នឹង ព្រំប្រទល់ឃុំទួលពង្រ ស្រុកម៉ាឡៃ

មាត្រា ៣ . ទីតាំងគោលដៅរបស់ឃុំតាគង់ ស្ថិតក្នុងភូមិកំប៉ែង ។

មាត្រា ៤ . បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ . រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាននិងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ៦១ អនក្រ.បក**

**ស្តីពីការបង្កើត ឃុំអូរបីជាន់ ចំណុះស្រុក**

**អូរជ្រៅ ខេត្តបន្ទាយមានជ័យ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ . ត្រូវបានបង្កើតឃុំអូរបីជាន់ ចំណុះស្រុកអូរជ្រៅ ដោយកាត់យកភូមិសាស្ត្រមួយចំនួន របស់ឃុំប៉ោយប៉ែត ឃុំនិមិត្ត និង ឃុំគីឡូ ក្នុងស្រុកអូរជ្រៅ និងឃុំស្ពានស្រែង ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។

មាត្រា ២ . ឃុំអូរបីជាន់ មានព្រំប្រទល់ដូចខាងក្រោម :

-ខាងជើងទល់ នឹង ព្រំប្រទល់ឃុំស្ពានស្រែង ស្រុកស្វាយចេក

-ខាងត្បូងទល់ នឹង ព្រំប្រទល់ឃុំគូប ឃុំនិមិត្ត ឃុំល្វា និងឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ

-ខាងលិចទល់ នឹង ព្រំប្រទល់ប្រទេសថៃ

-ងារកើតមក និង ព្រំប្រទល់កម្ពុជា គ្រប់គ្រងរដ្ឋ

មាត្រា ៣ ._ ទីតាំងគណៈកម្មការរៀបចំ ស្ថិតក្នុងភូមិសាស្ត្ររៀបចំ ។

មាត្រា ៤ ._ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាននិងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមហត្ថលេខាចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៤២២ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

មាត្រា ១ ._ ត្រូវបានតែងតាំងលោក ខេព ឆែន ជាអនុប្រធានក្រុមហ៊ុនអាកាសចរណ៍ភូមិន្ទកម្ពុជា ( Royal Air Cambodge ) ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ក្រុមហ៊ុនអាកាសចរណ៍ភូមិន្ទកម្ពុជា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និង

សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៤២៣ អនក្រ.តត

## ស្តីពីការជូនមេដាយមាសការងារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០៧ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រគល់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

## សម្រេច

**មាត្រា ១.**_ ត្រូវបានប្រគល់ មេដាយមាសការងារ ជាកិត្តិយសបណ្ណាការ ជូនលោក TAKAMASA OKAJIMA , Resident Engineer របស់ Oriental Consultant ជាការលើកតម្កើងស្នាដៃ និង ពលិកម្មនូវកម្លាំងកាយ ចិត្តប្រាជ្ញារបស់លោក ដែលបានចូលរួមកសាងស្ពានយ៉ាងសកម្ម ក្នុងគម្រោងជួសជុលផ្លូវជាតិលេខ ៦ និង ៧ ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន ។

**មាត្រា ២.**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៤២៤ អនក្រ.តត
## ស្ដីពីការតែងតាំងអភិបាល ស្រុក- ខណ្ឌ តាមបណ្ដាខេត្ត-ក្រុង

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា ១ .**_ ត្រូវបានតែងតាំងលោក **គឹម ឈាន** ជាអភិបាលស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។

**មាត្រា ២ .**_ បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

****

## អនុក្រឹត្យលេខ ៤២៥ អនក្រ.តត
## ស្ដីពីការផ្លាស់ប្ដូរមន្ត្រីរាជការ

★ ★ ★

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

មាត្រា ១ .- ត្រូវបានផ្លាស់ប្តូរអស់លោក ជាអភិបាលស្រុក អោយមកបំពេញការងារនៅសាលាខេត្តតាកែវ ដោយរក្សាឋានៈដដែល ដូចមានរាយនាមខាងក្រោម ៖

១-លោក **ហ៊ិត ឆែម** អភិបាលស្រុកត្រាំកក់

២-លោក **ឡៀម លី** អភិបាលស្រុកសំរោង

មាត្រា ២ .- បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៤២៦ អនក្រ.តត**

**ស្តីពីការតែងតាំងអភិបាល ស្រុក- ខណ្ឌ តាមបណ្តាខេត្ត-ក្រុង**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

មាត្រា ១ . ត្រូវបានតែងតាំងលោក **កែវ ប្រសិដ្ឋ** ជាអភិបាលស្រុកកំពង់ត្រាច [illegible]កំពត ។

មាត្រា ២ . បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវ អនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យលេខ ៤២៧ អនក្រ.តត**

**ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការ ប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់អភិបាលខេត្តកំពង់ចាម

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាស ស្ថាបនាជាតិ** ជូនសប្បុរសជន ០២រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ ខ្លួន ជួយឧបត្ថម្ភដល់ជីវភាពប្រជារាស្ត្រក្រីក្រនៅក្នុងភូមិដុះក្រោ ឃុំដុះ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដូចជា ជួយសង់ផ្ទះ ជីកអណ្តូងទឹក និងទិញគោសំរាប់ភ្ជួររាស់ ។ល។ ចំណាយអស់ទឹកប្រាក់សរុប ចំនួន ២៦.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ៖

១-លោកឧកញ៉ា សោ សេរីមុន្នី ហៅ សោ យ៉ាត

២-លោក សោ មុន្នីរស្មី

**មាត្រា ២ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ៤២៨ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ធំ

### សំរេច

**មាត្រា ១ ._** ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនអង្គការអន្តរជាតិ ដែលបានជួយកសាងសមិទ្ធផលនានារួម ចំណែកក្នុងការអភិវឌ្ឍន៍មូលដ្ឋាន នៅក្នុងខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោមនេះ ៖

១-សមាគម ABBA " ស្វីស " ជួយកសាងអាគារសិក្សា មៅផ្នែកុមារ និងផ្តល់តុ កៅអី សង់អណ្តូងទឹក នៅសាលាបឋមសិក្សា " មហារ " ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ចំណាយអស់ទឹកប្រាក់ ២០.០០០ ដុល្លារអាមេរិក ។

២-អង្គការ C. W.S ជួយកសាងអាគារសិក្សា ០១ ខ្នង មាន ៥ថ្នាក់ នៅភូមិ វល្លិហេរ ឃុំដីស្លាប់ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ និងជួយការងារអក្ខរកម្ម ចំណាយអស់ទឹកប្រាក់ចំនួន ២០.០០០ ដុល្លារអាមេរិក ។

៣-អង្គការ PASEC ឧបត្ថម្ភការងារបណ្តុះបណ្តាលបេតីចំណេះ និងកសាងសមត្ថភាពបុគ្គលិកសិក្សា និងជួយជួសជុលអាគារសិក្សា ផ្នែកបឋមសិក្សា ចំណាយអស់ទឹកប្រាក់ចំនួន ២១.៦៣៨ ដុល្លារអាមេរិក ។

មាត្រា ២._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៤២៩ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ស្ពឺ

### សម្រេច

មាត្រា ១. ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ទិជ័យ ឃ្មុំយទេជ** សញ្ជាតិស៊ុយអែត ជាប្រធានផ្នែកផ្គត់ផ្គង់ទឹកស្អាតនៃអង្គការ L.W.S ដែលបានជួយកសាងអណ្តូងទឹក ជូនប្រជាពលរដ្ឋកម្ពុជានៅក្នុងខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម បាត់ដំបង តាកែវ ព្រៃវែង និងភ្នំពេញ ចំណាយថវិកាសរុបអស់ចំនួន ៣០៥.២០០ ដុល្លារអាមេរិក ។

មាត្រា ២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងអភិបាលខេត្តកំពង់ស្ពឺត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ៤៣០ អនក្រ.តត
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សមាគមឥស្លាមកម្ពុជា

## សំរេច

**មាត្រា ១ .**_ ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ០២ រូប នៃសហភាពអារ៉ាប់អេមីរ៉ាត និង អ្នកទំនាក់ទំនងសប្បុរសជន ០១ រូប ដែលបានផ្តល់ថវិកាចំនួន ៥០.០០០ដុល្លារអាមេរិក សំរាប់សាងសង់សាលារៀន និងវិហារឥស្លាម នៅក្នុងស្រុកល្វាឯម និងស្រុកពញាក្រែក ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម ៖

១-លោក ស្តុបអេគិត **ម៉ះម៉ូត អាប់ឌុលឡោះ កាស៊ីម**

២-លោក អ៊ីសា ប៊ិន ណាស្សៀរ

៣-ឯកឧត្តម ម៉ាត់ លី

**មាត្រា ២ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសមាគមឥស្លាមកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ ដោយការ ទទួលបានមេដាយនេះ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

**អនុក្រឹត្យលេខ ៤៣១ អនក្រ.គត**
**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**សំរេច**

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ តាមលំដាប់ថ្នាក់ប្រគេន និងជូនសប្បុរសជនដែលបានឧបត្ថម្ភសំភារៈនិងថវិកា ជួយកសាងសមិទ្ធផលនានា ជាប្រយោជន៍ដល់សង្គមជាតិ និងពុទ្ធសាសនា នៅក្នុងរាជធានីភ្នំពេញ ចំណាយអស់ទឹកប្រាក់សរុបចំនួន ១៥៩.០២៥ ដុល្លារអាមេរិក និងប្រាក់រៀល ចំនួន ២.០០០.០០០រៀល ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ ៖

-មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ ច័ន្ទ កោសល្យ ព្រះចៅអធិការវត្ត ប្រជុំសាគរ

-មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក តាន់ ឡាក់ ប្រធានគណៈកម្មការវត្ត ប្រជុំសាគរ

២-ព្រះសង្ឃ និងពុទ្ធបរិស័ទចំណុះជើងវត្ត ប្រជុំសាគរ

-មេដាយសំរិទ្ធស្ថាបនាជាតិ :

១-សម្តេចព្រះមង្គលទេពាចារ្យ អ៊ុម ស៊ុម

២-ព្រះតេជគុណ ហ៊ុល សុវណ្ណ ព្រះចៅអធិការវត្តឱ្យពាស្តៅ និងជាព្រះអនុគណស្រុកឫស្សីកែវ រាជធានីភ្នំពេញ ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

អត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៤៣២ អនក្រ.តត
## ស្តីពីការតែងតាំង សមាជិក របស់ អគ្គលេខាធិការដ្ឋាន
## នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ១១/៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើត ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

## សំរេច

**មាត្រា ១ ._** តែងតាំងលោក **សួន លាងហៃ** ជាសមាជិករបស់ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដោយមានឋានៈស្មើនឹង ប្រធាននាយកដ្ឋាន ។

តួនាទី និង ភារកិច្ច ជាក់ស្តែង នឹងត្រូវបានកំណត់ជាក្រោយ ដោយប្រកាសរបស់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

**មាត្រា ២ ._** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ ._** ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និងសមាជិកទាំងអស់ នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្ត អនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៨៣ អនក្រ.តត
## ស្តីពីការតែងតាំងប្រធាន អគ្គនាយក
## របស់ធនាគារអភិវឌ្ឍន៍ជនបទ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈមូលដ្ឋាននៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ
- បានឃើញលក្ខន្តិកៈនៃធនាគារអភិវឌ្ឍន៍ជនបទ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.តត ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១.** តែងតាំងលោកឧត្តម សុន គន្ធ ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកសេដ្ឋកិច្ច កសិកម្ម ជាប្រធានអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ ។

**មាត្រា ២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិ នៃកម្ពុជា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៨៣៤ អនក្រ.គត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ប្រគេន ព្រះធេពសត្ថា ឈាយ ច្រឹក ព្រះរាជាគណៈថ្នាក់ចញ្ញាព្រះអនុគណគ្រុកពញ្ញា និងជាព្រះចៅអធិការវត្ត ច័ន្ទបុរីវង្ស ដែលបានបរិច្ចាគនូវបច្ច័យ សំរាប់ចូលរួមកសាងសមិទ្ធផលនានា ក្នុងព្រះពុទ្ធសាសនា និងអភិវឌ្ឍន៍ប្រទេសជាតិ មានទឹកប្រាក់សរុបចំនួន ៨៣.២១០ ដុល្លារអាមេរិក ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៨៣៥ អនក្រ.គត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

**សំរេច**

**មាត្រា ១ .**_ ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ប្រគេននិងជូនសប្បុរសជន ០២ រូប ដែលបានបរិច្ចាគបច្ច័យនិងធនធានផ្ទាល់ខ្លួន សំរាប់កសាងសមិទ្ធផលផ្សេងៗ ជូនជាតិ និងព្រះពុទ្ធសាសនា មានទឹកប្រាក់សរុបចំនួន ១.៣៩០.៧៥៤ ដុល្លារសហរដ្ឋអាមេរិក ដូចមានព្រះនាម និងនាមខាងក្រោមនេះ ÷

១-**ព្រះសាសនរំសី មួង រ៉ា** ព្រះរាជាគណៈថ្នាក់កិត្តិយស ទីប្រឹក្សាសម្តេចព្រះសង្ឃរាជគណមហានិកាយ ព្រះធម្មធរអនុគណស្រុកពញាឮ និងជាព្រះចៅអធិការវត្តមុនី ប្រសិទ្ធិវង្ស ។

២-ឯកឧត្តម អ្នកឧកញ៉ា **ម៉ែន សារុន** សមាជិកព្រឹទ្ធសភាជាតិ និងជានាយកក្រុមហ៊ុន **ម៉ែន សារុន** អហរ័ណ នីហរ័ណ ។

**មាត្រា ២ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៨៣៦ អនក្រ.តត

## ស្តីពីការជូនមេដាយសហមេត្រី

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយសេនាសហមេត្រី ជូនមន្ត្រីយោធាសហរដ្ឋអាមេរិក ០២ រូប ដែលបានមកបំពេញបេសកកម្មនៅព្រះរាជាណាចក្រកម្ពុជា ប្រកបដោយស្នាដៃល្អប្រសើរក្នុងការលើកស្ទួយទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ កម្ពុជា សហរដ្ឋអាមេរិកដូចមានរាយនាមខាងក្រោមនេះ ៖

១-វរសេនីយ៍ឯក **William N.Mc MILLAN**

២-វរសេនីយ៍ត្រី **Paul C. MARKS**

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៤៣៧ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនអ្នកជំនាញការអូស្ត្រាលី ០៦រូប នៃ "គំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា (CC JAP) ដែលបានមកជួយអភិវឌ្ឍន៍ការងារ

ប៉ូលិស យុត្តិធម៌ នៅព្រះរាជាណាចក្រកម្ពុជា តាមរយៈជំនួយរបស់អង្គការ AUSAID ដែលមាន ទឹកប្រាក់ប្រមាណ ០៥លានដុល្លារអូស្ត្រាលី ជូនមានរាយនាមខាងក្រោម ៖

**ក-មេដាយប្រាក់ ស្ថាបនាជាតិ :**

១-លោក **BILL KIDSTON**

២-លោក **BERNICE MASTERSON**

**ខ-មេដាយសំរិទ្ធ ស្ថាបនាជាតិ :**

១-លោក **ROD CHICK**

២-លោក **ALAN DREW**

៣-លោក **KEITH MARTIN**

៤-លោក **PETER SHEA**

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

**អនុក្រឹត្យលេខ ៤៣៨ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ឯកឧត្តម **ឯក សំអុល** តំណាងរាស្ត្រមណ្ឌលព្រៃវែង

សំរេច

**មាត្រា ១ .**_ ត្រូវបានប្រគល់ **មេដាយសុវត្ថិស្ថាបនាជាតិ** ជូនសប្បុរសជន ០២រូប រស់នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគថវិកា ជួយជីកអណ្តូងស្នប់ ទឹកស្អាត ជូនប្រជាពលរដ្ឋ នៅក្នុងខេត្តព្រៃវែង និងខេត្តតាកែវ ដូចមានរាយនាមខាងក្រោមនេះ ៖

១-លោកស្រី **ខ៊ែត សំអូន** បរិច្ចាគថវិកាចំនួន ៣.២៥០ ដុល្លារអាមេរិក

២-លោកគ្រូ **គុត កុសល** ( ធម្មឃោសារ ) និងឧបាសិកា **អ៊ិត ខ្សៃយន់** (សុធម្មា) បរិច្ចាគថវិកាចំនួន ១.៥០០ ដុល្លារអាមេរិក ។

**មាត្រា ២ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តតាកែវ និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

បាត្តលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ៤៣៩ អនក្រ.តត**

**ស្តីពីការជូនមេដាយសហមេត្រី**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១ .**_ ត្រូវបានប្រគល់ **មេដាយសេនាសហមេត្រី** ជូនលោក ព្រិន្ទបាលឯក **Henri GAUVIN** មន្ត្រី យោធាបារាំង ដែលមកបំពេញបេសកកម្ម នៅព្រះរាជាណាចក្រកម្ពុជា ទទួលបានស្នាដៃល្អប្រសើរ ក្នុងការលើក ស្ទួយទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ កម្ពុជា បារាំង ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

# ២-សេចក្ដីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៩៩

## សេចក្ដីសំរេចលេខ ៥២ សសរ

## ស្ដីពីការបង្កើតគណៈកម្មការសហប្រតិបត្តិការវិស័យថាមពលអគ្គិសនីជាមួយប្រទេស ថៃ ឡាវ វៀតណាម

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងសំណូមពរចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មការសហប្រតិបត្តិការវិស័យថាមពលអគ្គិសនី រវាងកម្ពុជាជាមួយប្រទេស ថៃ ឡាវ និងវៀតណាម ដែលរួមមានសមាសភាពដូចខាងក្រោម ៖

១-ឯ.ឧ **អ៊ិត ប្រាំង** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាប្រធាន

២-ឯ.ឧ **ម៉ុន អ៊ុំយ** អនុរដ្ឋលេខាធិការ ទីស្ដីការគណៈរដ្ឋមន្ត្រី ជាអនុប្រធាន

៣-ឯ.ឧ **ឡុង វិសាលោ** អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៤-ឯ.ឧ **អ៊ិត ឈន** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៥-ឯ.ឧ **ប្រាជ្ញ ស៊ុន** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ជាសមាជិក

៦-ឯ.ឧ **សួន សិទ្ធី** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា ជាសមាជិក

៧-ឯ.ឧ **នាង ផាត** អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិ ជាសមាជិក

៩-ឯ.ឧ **សេង សារឿន** អគ្គនាយករងនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ជាសមាជិក

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច :

-ពិនិត្យរៀបចំ សំរបសំរួល ការងារកិច្ចសហប្រតិបត្តិការវិស័យថាមពលអគ្គិសនីជាមួយប្រទេសថៃ ឡាវ និងវៀតណាម

-ពិនិត្យឯកសារកិច្ចព្រមព្រៀងសហប្រតិបត្តិការវិស័យថាមពលអគ្គិសនី ដើម្បីដាក់ជូនរាជរដ្ឋាភិបាលសំរេច ។

-តាមដាននឹងរាយការណ៍ ជូនរាជរដ្ឋាភិបាល ស្តីពីដំណើរការនៃការអនុវត្តន៍កិច្ចព្រមព្រៀងសហប្រតិបត្តិការ ។

**ប្រការ ៣ :** គណៈកម្មការមានក្រុមការងារជំនាញមួយជាជំនួយការ ដែលមានការិយាល័យអចិន្ត្រៃយ៍ តាំងនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បណ្តាខេត្តតាមព្រំដែន កម្ពុជា ថៃ កម្ពុជា ឡាវ កម្ពុជា វៀតណាមនិងសាមីជនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃកាលបរិច្ឆេទចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

★★★

## ៣-សារាចរ

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

### សារាចរលេខ ០៨ សរ

### ស្តីពីការរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ នៅពេលប្រលង

***

កន្លងមក ការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និង មធ្យមសិក្សាបឋមភូមិ បានទទួលលទ្ធផលល្អមួយកំរិតធំហើយ បើប្រៀបធៀបទៅនឹងលទ្ធភាពដែលយើងមាន និង សភាពការណ៍ជាក់ស្តែងនៃព្រះរាជាណាចក្រកម្ពុជាយើង ។ ប៉ុន្តែយើងនៅមានចំនុចសេសសល់ខ្លះៗ ដែលចាំបាច់ត្រូវតែលំអដូចជា :

-ការបង្កភាពអនាធិបតេយ្យ រំខានដល់ប្រក្រតីភាពនៃការប្រលង ។

-ការចែកចាយសន្លឹកឆ្លើយវិញ្ញាសា ឬក៏ផ្តល់ចម្លើយដល់បេក្ខជននៅក្នុងមណ្ឌលប្រឡង ។

-បាតុភាពបោះ គប់សំណៅចំលើយនៃវិញ្ញាសាចូលបន្ទប់ប្រឡង ។

-ការរត់សំរុកចូលក្នុងមណ្ឌលប្រឡង បន្ទប់ប្រឡងដើម្បីយកសំណៅចំលើយវិញ្ញាសាទៅអោយបេក្ខជន ។

-ការគំរាមកំហែងមេប្រយោគ ។

-បើកតៀមលក់ដូរ នំចំណី ជុំវិញមណ្ឌលប្រឡងដែលជាជំរកសំរាប់ជនខិលខូច បង្កភាពអនាធិបតេយ្យ ។

-បេសកកម្មការពារសុវត្ថិភាពមណ្ឌលប្រឡង នៅជាប់ភ្ជាប់ការរត់សំណៅ ចំលើយវិញ្ញាសាចូលមណ្ឌលបន្ទប់ប្រឡង រឺ ការការពារជនខិលខូចទៅវិញ ។

អាស្រ័យហេតុនេះ ដើម្បីអោយការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និង មធ្យមសិក្សាបឋមភូមិនៅដំណាច់ឆ្នាំសិក្សានេះ ប្រព្រឹត្តទៅក្នុងភាពប្រក្រតី មានសណ្តាប់ធ្នាប់រៀបរយល្អ ធានាបាននូវភាពយុត្តិធម៌ជូនបេក្ខជន និងមាតាបិតា ឬ អាណាព្យាបាលរបស់បេក្ខជន រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ ៖

១-គ្រប់ក្រសួង និង គ្រប់ខេត្ត -ក្រុង ត្រូវចាត់តាំងផ្សព្វផ្សាយ និង អប់រំអោយបានទូលំទូលាយជូនមន្ត្រីរាជការ បុគ្គលិក កម្មករ នៅទូទាំងក្រសួង ស្ថាប័ន និងខេត្ត-ក្រុង អោយយល់ពីលក្ខណការណ៍នៃការប្រឡងដែលផ្សព្វផ្សាយ ដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីចៀសវាងនូវប្រការដែលផ្ទុយនឹងបទបញ្ញត្តិនៃការប្រឡង ឬ ធ្វើអោយខូចសណ្តាប់ធ្នាប់រៀបរយ បង្កអោយមានភាពអនាធិបតេយ្យក្នុងពេលប្រឡង ។ សូមណែនាំអប់រំ បងប្អូន កូនចៅអោយមានជំនឿទុកចិត្តលើសមត្ថភាពរបស់ ខ្លួន និង លើរាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធ្វើអោយការងារប្រឡងមានលក្ខណៈយុត្តិធម៌ ជូនមាតាបិតា អាណាព្យាបាលសិស្សានុសិស្សទាំងអស់ ។ សូមបញ្ឈប់ជាដាច់ខាតនូវ គមន៍ដោយស្លូកប៉ាន់មេប្រយោគ ដោយទិញចំលើយវិញ្ញាសា ហើយជួលគេយកទៅសំណៅចូលទៅក្នុងបន្ទប់ប្រឡង និងបង្កអោយកូនចៅពាក់អាវុធ ឬជាតិផ្ទុះសំរាប់គំរាម គំហែងមេប្រយោគ ឬ បង្កើតឧបករណ៍ទំនាក់ទំនងសំរាប់បញ្ជូនខ្លឹមសារប្រធានវិញ្ញាសាចេញក្រៅដើម្បីអោយកូនចៅប្រឡងជាប់ ដែលជាលក្ខណៈផ្ទុយនឹងភាពយុត្តិធម៌ ។

២-ក្រសួងមហាផ្ទៃ ត្រូវណែនាំដល់សាលាខេត្ត-ក្រុង អោយស្នងការនគរបាល រៀបចំកំលាំងការពារសុខសុវត្ថិភាព និង រក្សាសណ្តាប់ធ្នាប់ សេចក្តីរៀបរយ តាមមណ្ឌលប្រឡងនីមួយៗ ក្នុងខេត្ត-ក្រុង របស់ខ្លួនអោយបានល្អប្រសើរ ។

៣-ចំពោះលោកគ្រូ អ្នកគ្រូជាមេប្រយោគ ដែលមានភារកិច្ចទទួលខុសត្រូវក្នុងការងារប្រឡង និងកងនគរបាល ដែលមានភារកិច្ចចូលរួមរក្សា ការពារសណ្តាប់ធ្នាប់ សេចក្តីរៀបរយ នៅតាមមណ្ឌលប្រឡង ត្រូវអនុវត្តអោយបានតាមភារកិច្ចរបស់ខ្លួន ក្នុងស្មារតីទទួលខុសត្រូវខ្ពស់បំផុត ធ្វើអោយការប្រឡងប្រព្រឹត្តទៅក្នុងភាពប្រក្រតី យុត្តិធម៌ ចៀសវាងដាច់ខាតនូវការប្រព្រឹត្តអ្វីដែលជាហេតុបណ្តាលអោយខូចវិន័យ និង សណ្តាប់ធ្នាប់នៃការប្រឡង ។

រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងកក់ក្តៅបំផុត ថាក្រសួង សាលាខេត្ត-ក្រុង ទាំងអស់នឹងលើកកម្ពស់ សមត្ថភាពក្នុងការគ្រប់គ្រងរដ្ឋបាល លើកកំពស់គុណធម៌ អនុវត្តតាមខ្លឹមសារ សារាចរណែនាំនេះឲ្យមាន ប្រសិទ្ធភាព ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## III- ការងារបណ្តាក្រសួង

### ១-ទីស្តីការគណៈរដ្ឋមន្ត្រី

### សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

**សេចក្តីសំរេចលេខ ៣៣ សសរ**

**ស្តីពីការបំពេញបន្ថែមសេចក្តីសំរេចលេខ ២៨ សសរ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសំរាប់ដឹកនាំ រៀបចំ និងដំណើរការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិតអោយចូលបំរើការងារក្នុងក្របខ័ណ្ឌ ក្រសួង-ស្ថាប័ននានា**

***

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញសេចក្តីសំរេចលេខ ២៨ សសរ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិតអោយចូលបំរើការងារក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននានា

- បានឃើញសេចក្តីសំរេចលេខ ២៤ សសរ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសំរាប់ដឹកនាំ រៀបចំ និងដំណើរការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិតអោយចូលបំរើការងារ ក្នុងក្របខ័ណ្ឌក្រសួងស្ថាប័ននានា
- តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សំរេច

**ប្រការ ១ :** គណៈកម្មការអន្តរក្រសួងមានភារកិច្ចដឹកនាំ រៀបចំ និងដំណើរការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិតអោយចូលបំរើការងារក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននានា ត្រួតពិនិត្យការប្រឡង និងផ្តល់សុពលភាពលើលទ្ធផលនៃការប្រឡងនេះ ។។

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការចាត់ចែង រៀបចំឯកសារគតិយុត្ត ទៅតាមបែបបទរដ្ឋបាលក្នុងពេលដឹកនាំ ការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិតអោយចូលបំរើការងារក្នុងក្របខ័ណ្ឌក្រសួងស្ថាប័ននានា ។

ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**សុខ អាន**

★★★

# ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៩៩

**ប្រកាសលេខ ៦៦៣ ឧក.ប្រក**

***

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ៧៧២/៩៩ គ.វ.ក ចុះថ្ងៃទី២៩ ខែ មីនា ឆ្នាំ១៩៩៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ១៩៥ ប.ស្ថ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៩ របស់ក្រសួងបរិស្ថាន

- បានឃើញលិខិតលេខ ០៥៨ ឈ.អ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៦ របស់សាលាខេត្តកណ្តាល
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ខេមបូឌា ស៊ុយហ្ស៊ុយគី ម៉ូទ័រ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៩៩

**សំរេច**

ប្រការ ១ : អនុញ្ញាតឲ្យក្រុមហ៊ុន ខេមបូឌា ស៊ុយហ្ស៊ុយគី ម៉ូទ័រ ( CAMBODIA SUZUKI MOTOR C0., Ltd ) តំណាងដោយលោក ស៊ីវ ថៃ សញ្ជាតិកម្ពុជា ភេទប្រុស អាយុ ៤៥ ឆ្នាំ អាសយដ្ឋាន ផ្ទះលេខ ២១៧ សង្កាត់ទួលទំពូង ២ ខណ្ឌចំការមន រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណលេខ ២៦៣៦១៦ ភ.ព ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៨៩ បង្កើត “ រោងចក្រតម្លើងទោចក្រយានយន្ត ” ដែលមានឈ្មោះថា “ រោងចក្រខេមបូឌា ស៊ុយហ្ស៊ុយគី ម៉ូទ័រ ” មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ ភូមិអង្គ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និង តំរោងសិក្សាសមិទ្ធិលទ្ធភាពបង្កើតរោងចក្រតម្លើងទោចក្រយានយន្ត ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផលហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតឲ្យ “ តម្លើងទោចក្រយានយន្ត ” ទៅតាមគំរូដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៥ : ក្រុមហ៊ុនត្រូវលើកបង្ហាញ “ ផ្លាកឈ្មោះរោងចក្រ ” របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀតនៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៦ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៧ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្តាល និងប្រធានក្រុមហ៊ុន ខេមបូឌា ស៊ុយហ្ស៊ុយគី ម៉ូទ័រ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងខ្លួនៗ ។

ប្រការ ៨ : ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ស៊ុយ សែម**

***

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៩៩

## ប្រកាសលេខ ៦៦៨ ឧក.ប្រក

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ១៩១៥/៩៨ គ.វ.ក ចុះថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ៦៤៥ ប.ស្ថ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៩៨ របស់ក្រសួងបរិស្ថាន
- បានឃើញការឯកភាពលើប្លង់គោលដៅ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៨ របស់សាលាក្រុងព្រះសីហនុ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន លីនស៍ ធិចជាយល៍ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៩៩

### សំរេច

**ប្រការ ១ :** អនុញ្ញាតឲ្យក្រុមហ៊ុន លីនស៍ ធិចជាយល៍ ( LIN'S TEXTILE CO.,LTD ) តំណាងដោយលោក LAM, CHING- MUI សញ្ជាតិចិន (តៃវ៉ាន់) ភេទប្រុស អាយុ ៨០ ឆ្នាំ អាសយដ្ឋាន 4/F, 21, Land-201, kang Loh Street, Donghu District, Taipei City, Taiwan, R.O.C កាន់លិខិតឆ្លងដែនលេខ M12053605 ចុះថ្ងៃ17-04-1996 បង្កើត " រោងចក្រផលិតក្រណាត់ចាក់ " ដែលមានឈ្មោះថា " រោងចក្រផលិតក្រណាត់ចាក់ លីនស៍ ធិចជាយល៍ " មានទីតាំងស្ថិតនៅផ្លូវលេខ១A មណ្ឌល៣ សង្កាត់១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

**ប្រការ ២ :** ការសាងសង់និងរៀបចំគ្រឿងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និង ដំណើរសិក្សាលទ្ធភាពបង្កើតរោងចក្រផលិតក្រណាត់ចាក់ដែលបានដាក់តំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អោយបានសំរេចក្នុងរយៈពេល០៦ខែដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

**ប្រការ ៣ :** ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

**ប្រការ ៤ :** រោងចក្រនេះត្រូវបានអនុញ្ញាតឲ្យ " ផលិតក្រណាត់ចាក់ "ទៅតាមគំរូដែលដាក់តំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលរបស់ក្រុមហ៊ុនត្រូវតែមានវិញ្ញាបនបត្របញ្ជាក់ផលិតកម្មពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវបើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀតនៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ក្រុងព្រះសីហនុ និងប្រធានក្រុមហ៊ុន លើនស៍ ពិចថាបេស៍ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ស៊ុយ សែម**

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩

## ប្រកាសលេខ ៦៦៦ ឧក.ប្រក
## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ១៨៥៩/៩៨ ព.វ.ក ចុះថ្ងៃទី២៥ ខែ សីហា ឆ្នាំ១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ៧៣៣ ប.ស្ថ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៩ របស់ក្រសួងបរិស្ថាន
- បានឃើញលិខិតលេខ ១៩៩ ល.អ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាខេត្តកណ្តាល ស្តីពីការអនុញ្ញាតឲ្យសាងសង់អគាររោងចក្រកាត់ដេរ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ហ្វារអ៊ីស្ទ ឆេកស្តាយល៍ លីមីធីដ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៩

សម្រេច

ប្រការ ១ : អនុញ្ញាតឲ្យក្រុមហ៊ុន ហ្វារអ៊ីស្ទ តិចស្ទាយល៍ លីមីធីដ (FAR EAST TEXTILE ,LTD) តំណាងដោយលោក តាង ជៀនកូ សញ្ជាតិកម្ពុជា ភេទប្រុស អាយុ ៥៥ ឆ្នាំ អាសយដ្ឋានផ្ទះលេខ ៥៥៩ សង្កាត់ ទឹកល្អក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណលេខ ២១៧៥២៣ ភ.ព ចុះថ្ងៃទី25-9-1992 បង្កើត " រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ " ដែលមានឈ្មោះថា " រោងចក្រកាត់ដេរ ហ្វារអ៊ីស្ទ តិចស្ទាយល៍ " មានទីតាំងស្ថិតនៅអគារ A នៃប្លង់សាងសង់ ចុះ ថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ១៩៩៩ ស្ថិតនៅភូមិព្រៃបឹង ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្ដាល ។

ប្រការ ២ : ការសាងសង់ និងរៀបចំគ្រឿងចក្រ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ ដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានសំរេចក្នុងរយៈពេល ០៣ ខែដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផលហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតឲ្យ "កាត់ ដេរ សំលៀកបំពាក់" ទៅតាមគំរូដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនបត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀតនៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្ដាល និងប្រធានក្រុមហ៊ុន ហ្វារអ៊ីស្ទ តិចស្ទាយល៍ លីមីធីត ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងខ្លួនៗ ។

ប្រការ ៩ : ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស៊ុយ សែម

★★★